រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៣២ សសរ
## ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល

-យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :**

ផ្ទេរសិទ្ធិជូនឯកឧត្តម **ម៉ុក មារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ទទួលបន្ទុកបន្ថែម ជារដ្ឋមន្ត្រីស្តីទីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួសឯកឧត្តម **ច័ន្ទ សុខអ៊ុច** ដែលត្រូវបានអញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេសដោយគិតចាប់ពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០១ រហូតដល់ឯកឧត្តម **ច័ន្ទ សុខអ៊ុច** អញ្ជើញវិលត្រឡប់វិញ ។

**ប្រការ ២ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាល ខេត្ត-ក្រុង និងឯកឧត្តម **ម៉ុក មារ៉េត** ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីស្តីពី
ហត្ថលេខា និងត្រា
**ស ខេង**

www.pheakdeylaw.com